# I - ខុទ្ទកាល័យព្រះមហាក្សត្រ

## ១_ព្រះរាជក្រម

### ព្រះរាជក្រម ជស/រកម/០៤៩៧/០២

**យើង**

**ព្រះបាទសម្តេចព្រះនរោត្តម សីហនុ រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី ទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស_រកត_១០៩៤_៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស_រកត_១០៩៤_៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស_រកម_០១៩៦_១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងផែនការ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង អំពីរដ្ឋមន្ត្រីក្រសួងផែនការ

## ប្រកាសអោយប្រើ

ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើផែនការអភិវឌ្ឍន៍ សេដ្ឋកិច្ច_សង្គមកិច្ច ៥ឆ្នាំលើកទី១ ១៩៩៦_២០០០ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៤ ខែ មករា ឆ្នាំ ១៩៩៧ នាសម័យប្រជុំលើកទី៧ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ ÷

## ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមលើផែនការអភិវឌ្ឍន៍
## សេដ្ឋកិច្ច_សង្គមកិច្ច ៥ឆ្នាំ លើកទី១ ១៩៩៦_២០០០

**មាត្រា ១** : អនុម័តយល់ព្រមលើផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច_សង្គមកិច្ច ៥ ឆ្នាំ លើកទី១ ១៩៩៦_២០០០ ដូចមានឯកសារភ្ជាប់មកជាមួយ ។

**មាត្រា ២** : រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តអនុវត្តផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច_សង្គមកិច្ច ៥ឆ្នាំ លើកទី១ ១៩៩៦_២០០០ នេះ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និង តាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

បានបង្គំទូលថ្វាយ និង ជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២

រដ្ឋមន្ត្រីក្រសួងផែនការ

ហត្ថលេខា

**ជា ចាន់តូ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះរាជហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី១ — ព្រះហស្តលេខា — **នរោត្តម រណឫទ្ធិ**

នាយករដ្ឋមន្ត្រីទី ២ — ហត្ថលេខា — **ហ៊ុន សែន**